ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៦៩៤.០៧.សហវ.ហក

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០០៩

## គោរពជូន

**ឯកឧត្តមនាយកខុទ្ទកាល័យព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ**
**ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ**

ខ្ញុំបានទទួលរួចហើយនាថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៩ នូវសេចក្តីប៉ាន់ប្រមាណព្យាក់ភាពគតិយុត្តិនៃចំណាយថវិកា និងការបរិច្ចាគនៃព្រះរាជទ្រព្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យជាតិ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ដោយមានទាំងព្រះហស្តលេខាផ្ទាល់របស់ព្រះបាទសម្តេចព្រះមហាវីរក្សត្រព្រះវររាជបិតាជាតិថែមទៀតផង។

ខ្ញុំសូមឯកឧត្តមមេត្តាក្រាបបង្គំទូលថ្វាយថ្លែងនូវអំណរព្រះគុណដ៏ជ្រាលជ្រៅ និងការវាយតម្លៃខ្ពស់ចំពោះព្រះកាយវិការដែលហូរចេញពីព្រះរាជហឫទ័យទុកដាក់ចំពោះតម្លាភាព និងគណនេយ្យភាព លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ព្រះមហាវីរក្សត្រ ។ យើងខ្ញុំទាំងអស់គ្នាចាត់ទុកថាជាគំរូដ៏វិសេសវិសាលដល់គ្រប់មន្ត្រីរាជការ នៃគ្រប់ក្រសួងស្ថាប័នជំនាញ ដែលកំពុងចូលរួមក្នុងកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជំហានទី២ ស្តីពីគណនេយ្យភាពហិរញ្ញវត្ថុ (Financial Accountability) ទន្ទឹមនឹងការពង្រឹងជំហានទី១ ស្តីពីភាពជឿទុកចិត្តបាននៃថវិកា (Budget Creditability)។

ឆ្លៀតឱកាសនេះដែរ រូបខ្ញុំ ក៏ដូចជាមន្ត្រីរាជការក្រោមឱវាទទាំងអស់ សូមឯកឧត្តមមេត្តាក្រាបថ្វាយព្រះពរបវរមហាប្រសើរថ្វាយចំពោះ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ ព្រះមហាវីរក្សត្រព្រះវររាជបិតាឯករាជ្យជាតិ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** សូមព្រះអង្គប្រកបដោយព្រះបរមសុខភាពល្អបរិបូណ៌ ព្រះជន្មាយុយឺនយូរ សុភមង្គល ហើយគង់ជាម្លប់ដ៏ត្រជាក់ជាយូរអង្វែងតទៅ សម្រាប់កូនចៅទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជា។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com